## ជំពូកទី ៤

## ប្រភពធនធាន

មាត្រា ១៤ .- ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច មានខ្ទង់ថវិកាមួយដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងផែនការ ។

មាត្រា ១៥ .- ធនធាន និងថវិការបស់ ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ត្រូវបានផ្គត់ផ្គង់ដោយថវិកាជាតិ និងហិរញ្ញប្បទានពីបរទេស អង្គការ និងធនាគារអន្តរជាតិ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

មាត្រា ១៦ .- អនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មការតាមដានដំណើរការបែងចែកជំនួយសំរាប់ការងារសង្គមកិច្ច និងបទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៧ .- ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងសមាជិកទាំងអស់នៃក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច ត្រូវទទួលបន្ទុករៀងៗខ្លួន អនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ជ.ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

សមាជិកអចិន្ត្រៃយ៍

ហត្ថលេខា

សុខ អាន

★★★

## អនុក្រឹត្យលេខ ៩០ អនក្រ.បក

## ស្តីពីការផ្ទេរផលិតផលឧបទិកា

## រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១.៧៥០ លានរៀល ( មួយពាន់ប្រាំពីររយហាសិបលានរៀល ) ពីជំពូក ១០ ( បៀវត្ស និង ប្រាក់បំណាច់ ) មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) របស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ។

**មាត្រា ២ .-** ឥណទានថវិកាក្នុងមាត្រា ១ ខាងលើ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ទូទាត់ឯកសណ្ឋាន ឆ្នាំ ២០០០ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ